# លោកគ្រូបង្គាបាត់ខ្លួន



កុមារីសាវី អ្នកណែនាំអំពី
ការប្រែប្រួលអាកាសធាតុ

# ប្អូនៗទាំងអស់ជាទីរាប់អាន

សូមស្វាគមន៍!

ខ្ញុំពិតជារីករាយណាស់ ដែលបានឃើញប្អូនៗកាន់សៀវភៅនេះឡើងដើម្បីអានជាការកំសាន្ត និងបង្កើនចំណេះដឹង។ ខ្ញុំសង្ឃឹមថា សៀវភៅដែលប្អូនៗកំពុងកាន់នេះ នឹងផ្តល់នូវចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុនៅក្នុងសហគមន៍នេសាទតំបន់ឆ្នេរ និងផ្តល់កម្លាំងចិត្តដល់ប្អូនៗក្នុងការប្រើប្រាស់ចំណេះដឹងទាំងនេះដើម្បីអនុវត្តបន្សុំានឹងការប្រែប្រួលអាកាសធាតុនៅក្នុងសហគមន៍របស់ប្អូនៗដោយផ្ទាល់។

តាមរយៈកូនសៀវភៅសង្ខេបខ្លីនេះ ខ្ញុំពិតជាសង្ឃឹមថាប្អូនៗនឹងរីករាយជាមួយដំណើរស្វែងរកវិជ្ជាអំពីការប្រែប្រួលអាកាសធាតុនាតំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជា។ ដូចប្អូនៗដឹងហើយថា ការប្រែប្រួលអាកាសធាតុកំពុងតែប៉ះពាល់ដល់សហគមន៍នៅតំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជាជាច្រើនផ្នែក ដែលជាហេតុនាំឲ្យអង្គការមជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារ និងស្ត្រីនៅកម្ពុជា បានជ្រើសរើសសហគមន៍ជាច្រើននៅតំបន់ឆ្នេរ ដូចជាប្រជាពលរដ្ឋនៅភូមិត្រពាំងសង្កែ ឃុំត្រពាំងសង្កែរ ស្រុកទឹកឈូ ខេត្តកំពត ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ តាមរយៈការបង្កើនការយល់ដឹងអំពីបរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ គាំទ្រការអភិរក្សធនធានជលផល និងធនធាន ធម្មជាតិតំបន់ឆ្នេរ ការវិនិយោគទៅលើគម្រោងផ្គត់ផ្គង់ទឹកស្អាត ក៏ដូចជាការបណ្តុះកូនកោងកាង និងមជ្ឈមណ្ឌលទេសចរណ៍ធម្មជាតិជាដើម។

ភូ តេង

នាយកប្រតិបត្តិ

មជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារ និងស្ត្រីនៅកម្ពុជា

ខេត្តកំពត ប្រទេសកម្ពុជា



ការលើកកម្ពស់សំឡេងរបស់កុមារ និងការចូលរួមរបស់ពួកគេក្នុងដំណើរការធ្វើការសម្រេចចិត្តជាមូលដ្ឋានគ្រឹះដើម្បីបន្សាំនឹងការប្រែប្រួលអាកាសធាតុមានន័យកាន់តែគ្រប់គ្រាន់...។ ជាអនុសាសន៍ កុមារ មន្ត្រីអប់រំ រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ត្រូវធ្វើការរួមគ្នាដើម្បីសមាហរណ៍កម្មទស្សនាទាននៃការប្រែប្រួលអាកាសធាតុ និងការយល់ដឹងពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយទៅក្នុងកម្មវិធីសិក្សាថ្នាក់បឋមសិក្សា និងអនុវិទ្យាល័យ។

នៅពេលមានព្យុះភ្លៀងលាយឡំនឹងផ្គររន្ទះ ជារឿយៗកុមារមិនដឹងត្រូវធ្វើអ្វីទេ។ ដោយសារពួកគេនៅសាលារៀនច្រើនជាងនៅផ្ទះជាមួយឪពុកម្តាយ ដូច្នេះចំណេះដឹងអំពីបញ្ហាទាំងនេះសំខាន់សម្រាប់កុមារក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយផ្សេងៗ។

- មជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារ និងស្រ្តីនៅកម្ពុជា (CWDCC) ធ្វើផែនទី និងវិភាគស្ថានភាពប្រែប្រួលអាកាសធាតុ និងសហគមន៍តំបន់ឆ្នេរ ក្នុងខេត្តកំពត

# មាតិកា៖


| | |
|---|---|
| លោកគ្រូបង្ហាបាត់ខ្លួន | ១ |
| កុមារីសារី អ្នកណែនាំអំពីការប្រែប្រួលអាកាសធាតុ | ៣២ |
| បញ្ជីពាក្យគន្លឹះ ៖ តើអ្នកស្គាល់ន័យរបស់ពាក្យទាំងនេះទេ? | ៤១ |
| សៀវភៅនេះចងក្រងឡើងដោយរបៀបណា | ៤៣ |


**កំណត់ចំណាំសម្រាប់ឪពុកម្តាយ ឬអាណាព្យាបាល៖**

ពាក្យគន្លឹះមួយចំនួន ត្រូវបានយកមកប្រើដោយមិនពន្យល់និយមន័យក្នុងគោលបំណងឲ្យកូនៗលោកអ្នកឆ្ងល់ ហើយចំណាយពេលស្វែងរកមើលន័យនៃពាក្យទាំងនោះ។

មានផ្តល់នូវ តំណប្រភពព័ត៌មាន មួយចំនួនដែលអាចជួយលោកអ្នកនិងកូនៗក្នុងការស្វែងរកន័យពាក្យ។

# អ្នកដឹងទេ?

ល្បាប់ភក់ ព្រៃកោងកាង និងស្មៅសមុទ្រដើរតួនាទីជាជម្រកការពារកូនត្រីតូចៗពីការប៉ុនប៉ងដោយសត្វចង្រៃផ្សេងៗ និងការពារពីចរន្តទឹកហូរខ្លាំង។

ល្បាប់ភក់ព្រៃកោងកាងក៏ជួយកាត់បន្ថយសំណឹកតំបន់ឆ្នេរពីខ្យល់ព្យុះ ពីការបង្ហូរកាកសំណល់ ពោលគឺកាត់បន្ថយការចម្លងរោគក្នុងទឹកសមុទ្រ និងដើរតួនាទី ជាអាងស្តុកកាបូន នៅពេលបំភាយអុកស៊ីសែន។





កូនត្រីតូចៗទាំងនេះកំពុងហែលទឹកកម្សាន្តនៅសាលាមត្តេយ្យនៅព្រៃកោងកាងតំបន់ត្រពាំងសង្កែ។

លោកបង្គា ជាគ្រូរបស់ពួកគេ។



លោកបង្គាចូលចិត្តលោតផ្លោត ផ្លោត។

គាត់ប្រាប់ថាគាត់ចូលចិត្តខ្យល់អាកាសបរិសុទ្ធ។

## អ្នកដឹងទេ?

សីតុណ្ហភាពខ្ពស់នៃទឹកសមុទ្រ បណ្តាលមកពីការប្រែប្រួល

អាកាសធាតុអាចធ្វើឱ្យកម្រិតអុកស៊ីសែននៅក្នុងទឹកថយចុះ

ហើយធ្វើឱ្យការរស់នៅនៃសត្វ

សមុទ្រមួយចំនួនជួបការលំបាក។

សិស្សត្រីតូចៗកំពុងចាប់អារម្មណ៍នឹងសមត្ថភាពពិសេសរបស់លោកគ្រូបង្គា។ ពួកគេចង់លោតដូចលោកគ្រូរបស់ពួកគេដែរ។ ពួកគេក៏សួរះ



"លោកគ្រូ តើអាចបង្ហាត់ពួកខ្ញុំឱ្យចេះលោតដូចលោកគ្រូដែរបានទេ?"

លោកគ្រូបង្គាឆ្លើយៈ "បាន! បាន! ងាយស្រួលទេ! "



"បិទភ្នែកឱ្យជិត។

ហើយស្រមៃទៅដល់អ្វីមួយដែលធ្វើឱ្យយើងរាំយ៉ាងរីករាយ។

ពេលយើងសប្បាយចិត្ត យើងទប់ខ្លួននៅស្ងៀមមិនបានទេ។

ពេលនោះយើងនឹងលោតឡើងលើហើយ!"

# អ្នកដឹងទេ?

នៅតំបន់ឆ្នេរនាខេត្តកំពត សម្បូរទៅដោយភូមិនេសាទជាជនជាតិខ្មែរឥស្លាម។ ត្រពាំងសង្កែជាផ្នែកមួយនៃសហគមន៍នេះ។

ការប្រែប្រួលអាកាសធាតុ និងការនេសាទលើសកំណត់បានធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់និងសហគមន៍ ដែលធ្វើឱ្យបរិមាណ និងគុណភាពនេសាទបានថយចុះ។



មិនយូរប៉ុន្មាន កូនត្រីទាំងនោះលោតផ្លោតចុះផ្លោតឡើងលើផ្ទៃទឹក។



វារី និងស្រីមុំរស់នៅក្នុងភូមិនេសាទក្បែរនោះ។ ក្មេងស្រីទាំងពីរនាក់ចូលចិត្តដើរកាត់តាមព្រៃកោងកាង ធ្វើខ្លួនដូចជាមន្រ្តីល្បាតព្រៃ។ ដោយពួកគេឃើញមនុស្សធំក្នុងភូមិឧស្សាហ៍ធ្វើបែបនេះ។

## អ្នកដឹងទេ?

ដើម្បីចៀសវាងព្រឹត្តិការណ៍គ្រោះមហន្តរាយ នៅឆ្នាំ២០០៨ភូមិនេសាទតំបន់ឆ្នេរ និងរាជរដ្ឋាភិបាលបានសម្រេចថាពួកគាត់នឹងនេសាទប្រកបដោយទំនួលខុសត្រូវនៅត្រពាំងសង្កែ។

សហគមន៍នេះទទួលខុសត្រូវក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

សមាជិកសហគមន៍ជាប់ឆ្នោត ល្បាតតំបន់ដោយទៀងទាត់ដើម្បីកាត់បន្ថយការនេសាទខុសច្បាប់ឬការកាប់ព្រៃកោងកាង។



ទាំងពីរនាក់ភ្ញាក់ផ្អើលមែនទែននៅពេលឃើញកូនត្រីលោតផ្លោតចុះផ្លោតឡើងលើផ្ទៃទឹក។

ពួកគេដើរថ្នមៗទៅកាន់ហ្វូងត្រីហើយសួរៈ

"សួស្ដីត្រីតូចៗ! ម៉េចបានជាលោតផ្លោតចុះផ្លោតឡើងបែបនេះ? ធ្វើយ៉ាងម៉េចទើបលោតបាន? "

ពីដំបូងកូនត្រីតូចៗភ្ញាក់ ប៉ុន្តែដោយសារពួកគេធ្លាប់ឃើញស្រីមុំ និងវារី ជាច្រើនដងមកហើយ

ដូច្នេះកូនត្រីតូចៗដឹងថាក្មេងទាំងពីរនាក់នេះមិនធ្វើបាបពួកគេឡើយ។

កូនត្រីតូចៗក៏ឆ្លើយ

“សាកលោតដែរទៅ!”

ត្រីទាំងអស់ស្រែកដោយរីករាយ។

"ត្រូវប្រយ័ត្ន ហើយព្យាយាមបន្តិចបើទោះជាអាចដួល!

បន្តព្យាយាម កុំឈប់! លោតផ្លោតៗសប្បាយណាស់ណា៎!"



លោកគ្រូបង្ហាត់របស់ពួកយើងបានប្រាប់ថា៖

"បិទភ្នែកឱ្យជិត។ ហើយស្រមៃទៅដល់អ្វីមួយដែលធ្វើឱ្យយើងរាំយ៉ាងរីករាយ។

ពេលយើងសប្បាយចិត្ត យើងទប់ខ្លួននៅស្ងៀមមិនបានទេ។

ពេលនោះយើងនឹងលោតឡើងលើហើយ!"




ក្មេងស្រីទាំងពីរ និងត្រីលោតចុះលោតឡើងយ៉ាងសប្បាយ រហូតទាល់តែហត់។
រាល់សប្ដាហ៍ ស្រីមុំ និងវារីទៅលេងមិត្តត្រីតូចៗរបស់ពួកគេ។



ល្ងាចមួយ ស្រីមុំ និងវារី ដើរកាត់ព្រៃកោងកាង ជាទីតាំងសាលាមត្តេយ្យដែលកូនត្រីហែលលេងជាប្រចាំ។

គេទាំងពីររន្ធត់ជាពន់ពេកនៅពេលឃើញព្រៃកោងកាងនៃសាលាមត្តេយ្យកូនត្រីត្រូវបាន
កាប់បំផ្លាញ។ ពួកគេមើលទៅក្នុងទឹក ឃើញតែមិត្តត្រីតូចមួយរបស់ពួកគេប៉ុណ្ណោះ។

"តើលោកគ្រូបង្គានៅឯណា?" ពួកគេសួរទៅកាន់កូនត្រី



កូនត្រីតូចបានរៀបរាប់ពីរឿងសោកសៅដែលបានកើតឡើងកាលពីសប្តាហ៍មុន៖

"ពេលយប់ស្ងាត់មានបុរសពីរនាក់បានមកទីនេះ ហើយកាប់ដើមកោងកាងសាលាមត្តេយ្យ។

ពួកគេចាប់លោកគ្រូបង្គា ព្រមទាំងក្រុមគ្រួសារ និងត្រីផ្សេងៗទៀតយកទៅ។"

"ខ្ញុំរួចខ្លួនបានដោយសារខ្ញុំពួនក្នុងស្មៅសមុទ្រ។"



# អ្នកដឹងទេ?

ការកាប់ព្រៃកោងកាងគឺជាទង្វើខុសច្បាប់ ហើយច្បាប់បានចែងយ៉ាងច្បាស់អំពីការគ្រប់គ្រងតំបន់នេសាទ និងរបៀបនេសាទ។ ទោះជាយ៉ាងនេះក្តី ពេលខ្លះសមាជិកសហគមន៍បានកាប់ដើមកោងកាងដើម្បីដុតធ្វើធ្យូង ឬទៅនេសាទនៅតំបន់ហាមឃាត់។ ពួកគេធ្វើបែបនេះព្រោះពួកគេគ្មានមធ្យោបាយផ្សេងទៀតដើម្បីចិញ្ចឹមគ្រួសារ។



ស្រីមុំ និងរារី ខឹងខ្លាំងណាស់ នៅពេលឮរឿងនេះ។

ពួកគេមិនចង់ជឿទាល់តែសោះថាមានគេកាប់ព្រៃកោងកាងយ៉ាងអនាធិបតេយ្យបែបនេះ។

ស្រីមុំនិយាយខ្លាំងៗ៖

"អូ ! ខ្ញុំខឹងខ្លាំងណាស់ ប៉ុន្តែខ្ញុំមិនដឹងធ្វើអ្វីកើត

បើខ្ញុំនិងវារីឯងគ្រាន់តែជាក្មេងស្រីតូចៗ។"



វារីនិយាយដោយក្ដីសង្ឃឹមថា៖



"ត្រូវតែមានមធ្យោបាយដើម្បីទប់ស្កាត់រឿងនេះកុំឱ្យកើតឡើងទៀត។

តោះទៅសួរអ្នកគ្រូ លី ឆាយ គាត់នឹងអាចមានយោបល់ខ្លះសម្រាប់យើង។

អ្នកគ្រូ លី ឆាយ ជាគ្រូបង្រៀនរបស់ក្មេងស្រីទាំងពីរ។

គាត់តែងតែលើកប្រធានបទបរិស្ថានមកជជែកជាមួយសិស្ស។

ក្មេងស្រីទាំងពីរទៅផ្ទះអ្នកគ្រូ លី ឆាយ ហើយរៀបរាប់ពីការបាត់បង់មិត្តត្រីរបស់ពួកគេ។

អ្នកគ្រូ លី ឆាយស្តាប់យ៉ាងយកចិត្តទុកដាក់។



គាត់ញញឹមហើយនិយាយទៅកាន់ក្មេងស្រីទាំងពីរ៖

"អ្នកគ្រូសប្បាយចិត្តណាស់ដែលកូនៗយករឿងនេះមកប្រាប់អ្នកគ្រូ។"

"អ្នកគ្រូប្រាកដជាជួយមិនឱ្យរឿងនេះកើតឡើងម្តងទៀតទេ ប៉ុន្តែ

កូនៗត្រូវរង់ចាំបន្តិចណា! ពីព្រោះបើយើងចង់ធ្វើការផ្លាស់ប្តូរគឺត្រូវការពេលវេលាបន្តិច។ ទោះយ៉ាង

ណា ពួកយើងនឹងមិនបោះបង់ចោលការព្យាយាមនោះដែរ។"

អ្នកគ្រូ លី ឆាយ បន្ត៖

"កាលពីប៉ុន្មានទសវត្សរ៍មុន មានរឿងរ៉ាវកើតឡើងអាក្រក់ជាងនេះទៅទៀត។ ព្រៃកោងកាង និងត្រីស្ទើរទាំងអស់ត្រូវបានបាត់បង់។

ទីបំផុត សហគមន៍ប្តេជ្ញាចិត្តរួមសាមគ្គីគ្នាដើម្បីធ្វើឱ្យត្រពាំងសង្កែទៅជាកន្លែងមួយសុខសាន្តសម្រាប់ជីវិតមនុស្សសត្វ។"

"គេសម្រេចចិត្តថាឈប់កាប់ដើមឈើ និងឈប់នេសាទលើសកំណត់។"



ប៉ុន្តែពេលខ្លះ ប្រជាពលរដ្ឋកាប់ព្រៃកោងកាងទាំងខុសច្បាប់។


ស្រីមុំនៅតែឆ្ងល់៖
"ហេតុអ្វីពួកគេធ្វើបែបនេះ?"




## អ្នកដឹងទេ?

ប្រភពចំណូលរបស់សហគមន៍ភាគច្រើនបានមកពីការនេសាទ និងការដាំស្រូវ។ ប្រមាណមួយភាគបួននៃប្រជាពលរដ្ឋមានអាជីវកម្មខ្នាតតូច ដូចជាលក់ចាប់ហួយ ហើយប្រហែលមួយភាគបីរកប្រាក់ចំណូលបានដោយធ្វើការនៅកសិដ្ឋានរបស់អ្នកដទៃ ធ្វើការរោងចក្រសម្លៀកបំពាក់ និងធ្វើការងារសំណង់។

ជាធម្មតាអ្នកនេសាទ ឬស្ត្រី អាចរកប្រាក់ចំណូលបាន ៤ម៉ឺនរៀល ប្រមាណ១០ដុល្លារក្នុងមួយថ្ងៃ។

# អ្នកដឹងទេ?

បើតាមសម្ដីរបស់ប្រធានសហគមន៍ មនុស្សបីនាក់ក្នុងចំណោម បួននាក់ក្នុងសហគមន៍ចូលរួមយ៉ាងសកម្មក្នុងការងារការពារ ធនធានធម្មជាតិ។

គណៈកម្មការការពារជលផលបានប្រឹងប្រែងអស់ពី សមត្ថភាព ក្នុងការអប់រំសហគមន៍ឱ្យយល់ពីតម្លៃនៃ និរន្តរភាពជលផល និងការអភិរក្សព្រៃកោងកាង។



" អ្នកគ្រូសួរទៅក្មេងទាំងពីរ៖ "នៅពេលអ្នកភូមិ និងអ្នកជិតខាង រៀបចំសកម្មភាពដើម្បីទប់ស្កាត់ការកាប់បំផ្លាញព្រៃ តើកូនៗនឹងចូលរួមពន្យល់អ្នកភូមិអំពីសារៈសំខាន់នៃព្រៃកោងកាង និងស្មៅសមុទ្រដែរឬទេ? "

ក្មេងស្រីទាំងពីរងក់ក្បាលយល់ព្រម។ ពួកគេរំភើបដែលអាចជួយក្នុងរឿងនេះបាន។

ជាយូរណាស់មកហើយដែលពួកគេចង់រួមចំណែកជាមួយសហគមន៍ក្នុងកិច្ចការពារបរិស្ថាន។



"តើពេលណាពួកយើងអាចចាប់ផ្តើមបានទៅ?" ពួកគេសួរ

អ្នកគ្រូលីឆាយមើលទៅក្រៅបង្អួច ក៏ឃើញមេឃងងឹត

"ឥឡូវនេះល្ងាចណាស់ហើយ ទៅផ្ទះសម្រាកសិនទៅ។
ចាំស្អែកចាំចាប់ផ្ដើម។"





“នេះយកឆ័ត្រទៅកូនៗ”

“បច្ចុប្បន្ននេះអាកាសធាតុ វាពិបាកស្មានណាស់។ ជួនកាលអាចមានភ្លៀងធ្លាក់ខ្លាំង ទាំងនៅខែមករាក៏មាន!”

យប់នោះក្មេងស្រីទាំងពីរចូលគេងទាំងអារម្មណ៍រំភើប។



ស្រីមុំយល់សប្តិឃើញ ក្លាយជាមន្ត្រីបរិស្ថាននៅពេលនាងធំឡើង។

វារីយល់សប្តិឃើញមិត្តត្រីរបស់នាង។



..." បិទភ្នែកឱ្យជិត។

ហើយស្រមៃទៅដល់អ្វីមួយដែលធ្វើឱ្យយើងរាំយ៉ាងរីករាយ។

ពេលយើងសប្បាយចិត្ត យើងទប់ខ្លួននៅស្ងៀមមិនបានទេ។

ពេលនោះយើងនឹងលោតឡើងលើហើយ។"



ចប់



# កុមារីសារី អ្នកណែនាំអំពីការប្រែប្រួលអាកាសធាតុ



# សកម្មភាពទី១

កត់ត្រាអំពីអាកាសធាតុរាល់ថ្ងៃ រយៈពេលមួយអាទិត្យ។ សីតុណ្ហភាពប៉ុន្មាន? មេឃភ្លៀងទេ? ពពកច្រើនទេ?

សុំមនុស្សធំឲ្យជួយក្នុងការប្រើពាក្យដើម្បីពិពណ៌នាធាតុអាកាសប្រចាំថ្ងៃ។

ថ្ងៃទី១:

ថ្ងៃទី២:

ថ្ងៃទី៣:

ថ្ងៃទី៤:

ថ្ងៃទី៥:

ថ្ងៃទី៦:

ថ្ងៃទី៧:

តើប្អូនសង្កេតឃើញធាតុអាកាស ផ្លាស់ប្តូរទេពីមួយថ្ងៃទៅមួយថ្ងៃ ? ថ្ងៃខ្លះក្តៅខ្លាំងជាងធម្មតា ថ្ងៃខ្លះភ្លៀងហើយថ្ងៃខ្លះទៀតរាំង?

**អាកាសធាតុ** គឺសំដៅលើមធ្យមភាគធាតុអាកាសនៅតំបន់ណាមួយជាក់លាក់ក្នុងរយៈវែង អាចរាប់ទសវត្សរ៍ ឬសតវត្សរ៍ ឬសហស្សវត្សរ៍។

**ធាតុអាកាស** អាចផ្លាស់ប្តូរបានជារៀងរាល់ថ្ងៃ រាល់ពេល ឬរាល់ឆ្នាំ។

# ពេលនេះមានអ្វីខុសពីមុន?

## សកម្មភាពទី២៖

នៅពេលកូនៗទៅលេងផ្ទះបងប្អូន សូមសួរមនុស្សធំ ពីរសំនួរ៖

១) ពេលអ្នកនៅអាយុប្រហែលខ្ញុំ តើភូមិ ឬសហគមន៍មានសភាពយ៉ាងម៉េច?

______________________________________________________________________

២) អាកាសធាតុខុសពីមុនដូចម្តេច?

______________________________________________________________________

ការប្រែប្រួលអាកាសធាតុតែងតែកើតមានឡើង ។ កាលពីមុន ការប្រែប្រួលទាំងនេះបង្កឡើងពីកត្តាធម្មជាតិ ។ ប៉ុន្តែសម្រាប់បច្ចុប្បន្ននេះ ការដុតឥន្ធនៈហ្វូស៊ីល ការកាប់បំផ្លាញព្រៃឈើទ្រង់ទ្រាយធំ និងសកម្មភាពផ្សេងៗទៀតរបស់មនុស្ស បានបង្កើនការបំភាយឧស្ម័នពុលដូចជាកាបូនឌីអុកស៊ីតទៅក្នុងបរិយាកាស ដែលជាកត្តាចម្បងនៃការប្រែប្រួលអាកាសធាតុ។

## អឺ...ដូច្នេះយ៉ាងម៉េច?

ផែនដីកើនកម្ដៅលឿនជាងពេលមុនៗ ទៅទៀត ដែលធ្វើឱ្យមានការប្រែប្រួលបរិមាណទឹកភ្លៀងនិងការកើនឡើងនូវគ្រោះមហន្តរាយកាចសាហាវដូចជាព្យុះជាដើម។

## សកម្មភាពទី៣

តើប្អូនអាចស្មានដឹងពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដែរឬទេ? (អាចសុំមនុស្សធំជួយបាន)

រ_ក_ម្ដៅ

កំណើ_កម្ព_ទឹក_មុ_

កា_ _លា_ដុំទឹ_ក_

រលកកម្ដៅ

កំណើនកម្ពស់ទឹកសមុទ្រ

ការរលាយដុំទឹកកក



## តើអ្វីទៅជាផលវិបាកនៃការប្រែប្រួលអាកាសធាតុទាំងនេះ?

- ការរីករាលដាលនៃជម្ងឺ។
- រដូវផ្លាស់ប្ដូរមិនទៀងអាចបង្កផលប៉ះពាល់ដល់កសិករ និងលទ្ធភាពក្នុងការដាំដុះ។
- ការខូចខាតនៃគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ រួមមានផ្លូវថ្នល់ ស្ពាន ផ្លូវទឹកនិងសេដ្ឋកិច្ចបន្ទាប់ពីព្រឹត្តិការណ៍ធម្មជាតិកាចសាហាវនានា។
- បរិស្ថានធម្មជាតិផ្លាស់ប្ដូរបណ្ដាលឱ្យបាត់បង់ដែនជម្រក  និងពូជសត្វ។

# ការប្រែប្រួលអាកាសធាតុនៅត្រពាំងសង្កែ

សហគមន៍នេសាទត្រពាំងសង្កែ គឺជាតំបន់អភិរក្សនិងសិក្សា ស្ថិតក្នុងឃុំត្រពាំងសង្កែ ស្រុកទឹកឈូរ ខេត្តកំពតប្រទេសកម្ពុជា។ ទីតាំងនេះត្រូវបានបង្កើតឡើងដើម្បីការពារធនធានធម្មជាតិក្នុងតំបន់រួមមានវាលល្បាប់ភក់ព្រៃកោងកាង ឆ្នេរ និងពូជដើមរបស់ត្រី។ សហគមន៍នេះធ្វើការផ្តោតលើអេកូទេសចរណ៍ និងសកម្មភាពបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ជារៀងរាល់ឆ្នាំមានមនុស្សប្រហែល ៥០០០-៦០០០ នាក់មកលេងសហគមន៍ត្រពាំងសង្កែ។

## តើអេកូទេសចរណ៍គឺជាអ្វី?

វាជាទេសចរណ៍ដែលផ្តោតលើការ រួមគ្នាអភិរក្ស ក៏ដូចជាដំណើរកំសាន្តប្រកបដោយមនសិការ និងដែលជួយគាំទ្រដល់សហគមន៍ក្នុងគោលបំណងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន។



កសិករមិនអាចធ្វើការដាំដុះបានទេ។

រាល់ថ្ងៃនេះអាកាសធាតុក្តៅជាងមុនហើយមនុស្ស
ពិបាកធ្វើការដោយសារតែកម្តៅកើនឡើង។

មនុស្សពេញវ័យក្នុងសហគមន៍ត្រូវចាកចេញពីក្រុមគ្រួសារ
របស់ពួកគេ ហើយទៅទីក្រុងដើម្បីរកការងារធ្វើ។

ប្រជាពលរដ្ឋត្រូវធ្វើការយូរជាងមុនដើម្បីរកត្រី
បានគ្រប់គ្រាន់យកមកផ្គត់ផ្គង់គ្រួសារ។

ខ្លួនស្អិត ហើយនៅមិនស្រណុកពេលរដូវក្តៅ។

# សម្រង់ពាក្យសម្គាល់

តើប្អូនអាចរកនិយមន័យនៃពាក្យខាងក្រោមបានប៉ុន្មាន?

| | |
|---|---|
| បន្សាំ | Adaptation |
| បរិយាកាស | Atmosphere |
| អាងស្តុកកាបូន | Carbon Sink |
| គ្រោះមហន្តរាយ | Catastrophic |
| សតវត្សរ៍ | Century |
| ជនជាតិខ្មែរឥស្លាម | Cham |
| តំបន់ឆ្នេរ | Coastal |
| ឃុំ | Commune |
| ប្រកបដោយមនសិការ | Conscious |
| ការឯកភាពដោយមតិភាគច្រើន | Consensus |

| | |
|---|---|
| ផលវិបាក | Consequence |
| ការអភិរក្ស | Conservation |
| ការបំពុល ឬធ្វើឲ្យកខ្វក់ | Contamination |
| ទសវត្សរ៍ | Decade |
| ការកាប់បំផ្លាញព្រៃឈើ | Deforestation |
| ប្រេងឥន្ធនៈផូស៊ីល | Fossil Fuels |
| ដែនជម្រក | Habitat |
| សហស្សវត្សរ៍ | Millennium |
| ជនជាតិដើម | Native |
| ពូជ | Species |
| និរន្តរភាព | Sustainable |
| វាលល្បាប់ភក់ | Swamp |
| គមនាគមន៍ | Transportation |

# សៀវភៅនេះចងក្រងឡើងរបៀបណា

សៀវភៅនេះកើតឡើងដោយមានការផ្តល់មូលនិធិពីធនាគារអភិវឌ្ឍន៍អាស៊ី គម្រោងជំនួយបច្ចេកទេស៖ ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍ ដែលគាំទ្រដោយកម្មវិធីសាកល្បងភាពធន់នឹងអាកាសធាតុ (PPCR) នៃមូលនិធិវិនិយោគអាកាសធាតុ (CIF)។

អង្គការភ្លែនអន្តរជាតិ កម្ពុជានិងអង្គការដៃគូ CWDCC (មជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារ និងស្ត្រីនៅកម្ពុជា) ធ្វើការងារដើម្បីបង្កើនការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុនៅក្នុងសហគមន៍តំបន់ឆ្នេរនៅខេត្តកំពត គាំទ្រសកម្មភាពល្បាត និងផ្តល់មូលនិធិដល់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធអេកូទេសចរណ៍ដើម្បីធានាប្រាក់ចំណូលរយៈពេលវែងព្រមទាំងការលើកទឹកចិត្តចំពោះការការពារព្រៃកោងកាង និងសកម្មភាពការពារធនធានជលផលនៅក្នុងតំបន់គោលដៅ។ គម្រោងនេះមានរយៈពេល ១៩ខែហើយស្ថិតក្រោមគម្រោងបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ - យន្តការគាំទ្រសង្គមស៊ីវិល (MCRDP-CSSM) ។

ព័ត៌មានមូលដ្ឋានអំពីសហគមន៍ដែលបានចែកចាយនៅក្នុងសៀវភៅនេះ បានចងក្រងឡើងពេលចាប់ផ្តើមគម្រោង (២០១៥) ពីការធ្វើការសិក្សាវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ ដែលបានធ្វើឡើងជាមួយក្រុមបុរស ស្ត្រី និងកុមារ និងពីការស្រាវជ្រាវបន្ថែម (២០១៧) ដែលធ្វើឡើងដោយទីប្រឹក្សាឯករាជ្យ រួមមានការពិភាក្សាក្រុម ការស្ទាបស្ទង់មតិនិងការសម្ភាស។

# តំណប្រភពព័ត៌មាន មានសារៈប្រយោជន៍៖

| | |
|---|---|
| www.nationalgeographic.com/family | ផ្តល់ព័ត៌មានបែបកុមារមេត្រីអំពីប្រធានបទជាច្រើន រួមមានតាំងពីការប្រែប្រួលអាកាសធាតុដល់សត្វព្រៃ ជាភាសាអង់គ្លេស |
| climatekids.nasa.gov/big-questions | សេចក្តីណែផ្តល់ដោយអង្គការ NASA ងាយៗសម្រាប់កុមារស្វែងយល់ អំពីការប្រែប្រួលអាកាសធាតុ ជាភាសាអង់គ្លេស |
| www.camclimate.org.kh/km | វេបសាយផ្លូវការរបស់កម្ពុជា អំពីការប្រែប្រួលអាកាសធាតុ ជាភាសាខ្មែរ |
| www.camclimate.org.kh/en | វេបសាយផ្លូវការរបស់កម្ពុជា អំពីការប្រែប្រួលអាកាសធាតុ ជាភាសាអង់គ្លេស |
| dictionary.cambridge.org | វេបសាយ ផ្តល់ការពន្យល់អត្ថន័យពាក្យផ្សេងៗ ជាភាសាអង់គ្លេស |
| www.everyculture.com | វេបសាយ ផ្តល់ការស្វែងយល់អំពីវប្បធម៌ផ្សេងៗជុំវិញពិភពលោក ភាសាអង់គ្លេស គឺជាកន្លែងដែលអាចស្វែងរកព័ត៌មានអំពីសហគមន៍ជនជាតិខ្មែរឥស្លាម។ |
| https://www.facebook.com/kampotmangrove.forest | គេហទំព័រហ្វេសប៊ុករបស់សហគមន៍ត្រពាំង សង្កែ |

** តំណប្រភពព័ត៌មាន ទាំងនេះមានដំណើរការនៅពេលចងក្រងសៀវភៅនេះ។*

*** តំណប្រភពព័ត៌មាន ត្រូវបានប្រើប្រាស់ ដើម្បីជាជំនួយក្នុងការសរសេរសៀវភៅនេះឡើង។*



សៀវភៅនេះនិពន្ធដោយអ្នកស្ម័គ្រចិត្តពីអង្គការភ្លែនអន្តរជាតិកម្ពុជា និង អង្គការ មជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារនិងស្ត្រីក្នុងប្រទេសកម្ពុជា (CWDCC, www.cwdcc.org) ដែលទទួលបានការឧបត្ថម្ភពីគម្រោងធនាគារអភិវឌ្ឍន៍អាស៊ីក្នុងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍។

រៀបចំគំនូរ និងរូបភាពដោយវិចិត្រករ N. Joseph